# ក្នុងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៧៧

ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១

សាលដីកា

លេខ: ៣៣៣

ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោកស្រី [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៨៨(គ) ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៧៧ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូល។

<u>ពីបទ:</u> ប្លន់ (ឆក់ខ្សែក) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ជនជាប់ចោទ៖

១-ឈ្មោះ [redacted] [redacted]រៀង (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ [redacted] [redacted]ាល ចាប់ខ្លួននៅផ្ទះជួល សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]វើត (ស) ម្តាយឈ្មោះ [redacted]ផល (រ) នៅលើរ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩។



Scanned by CamScanner

២-ឈ្មោះ [redacted] រម្យ ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីមិនពិតប្រាកដ [redacted] សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩។

៣-ឈ្មោះ [redacted] ធឿន ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីជាងកាត់សក់ [redacted] សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៥ឆ្នាំ ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ៣E១ ផ្លូវលេខ៣១៦ ក្រុមទី៣៦ សង្កាត់ផ្សាដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោងប្រហែល១៧:០០នាទី កំលាំងល្បាតរបស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាលនៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ បានល្បាតត្រង់ចំណុចស្តាតអូឡាំពិក បានឃើញជនសង្ស័យចំនួន៣នាក់ ជិះម៉ូតូ២គ្រឿង មួយម៉ាកស្មាសរីវ៉ូពណ៌ខ្មៅឆ្នាំ២០០៧ ពាក់ស្លាកលេខ ភ.ព ១អូ៦២០០, ទីពីរម៉ាក ហុងដា១០០ពណ៌ខ្មៅឆ្នាំ១៩៩៩ បានធ្វើសកម្មភាពឆក់ខ្សែកពីនារីម្នាក់ដែលកំពុងជិះម៉ូតូម៉ាកឌុបម្នាក់ឯង ដោយមានការស្រែកឱ្យជួយពីជនរងគ្រោះ កម្លាំងយើងបានដេញចាប់ លុះមកដល់ចំណុចផ្លូវមុនីវង្សកែងផ្លូវ៣១០ ទើបធ្វើការឃាត់ខ្លួនជនសង្ស័យបាន០៣នាក់ ១-ឈ្មោះ [redacted] ធឿន, ២-ឈ្មោះ [redacted] អៀង, ៣-ឈ្មោះ [redacted] រម្យ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖

-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើឈ្មោះ [redacted] អៀង, ឈ្មោះ [redacted] រម្យ, ឈ្មោះ [redacted] ធឿន ពីបទៈ ប្លន់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ។

-ដូច្នេះសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] អៀង, ឈ្មោះ [redacted] រម្យ, និងឈ្មោះ [redacted] ធឿន ទៅជំនុំជម្រះ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៨៣ (កប៥) ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច៖

១-ផ្តន្ទាទោសលើ:

ក-ឈ្មោះ [redacted] អៀង ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៧ឆ្នាំ(ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។



Scanned by CamScanner

ខ-ឈ្មោះ [redacted] ធឿន ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។

គ-ឈ្មោះ [redacted] រម្យ ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។ ពីបទៈ ប្លន់ (ឆក់ខ្សែក) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា០៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-វត្ថុតាងរួមមានៈ

-ម៉ូតូ០១គ្រឿង ម៉ាកស្មាសវីវ៉ូ ពណ៌ខ្មៅ សេរីឆ្នាំ២០០៧ ពាក់ស្លាកលេខភ្នំពេញ១O៦២៩០ លេខតួ និងលេខម៉ាស៊ីនE៤៥០TH២១០៧៩៣។

-ម៉ូតូ០១គ្រឿងម៉ាកC១១០ ពណ៌ខ្មៅ សេរីឆ្នាំ១៩៩៩ ផលិតនៅប្រទេសចិន ពាក់ស្លាកលេខ ណ ៣៤៦២ ភព១ ដែលមានតួលេខ និងលេខម៉ាស៊ីន EPSOMG-៣, ១០៤៧២០៤៤។

ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

-ខ្សែកផ្កាកទីនចំនួន១ខ្សែ ប្រវែង២តឹកកន្លះ ត្រូវប្រគល់ឱ្យឈ្មោះ [redacted] ផល្លី តាមកំណត់ហេតុប្រគល់សម្ភារៈចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៩ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាលរួចហើយ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]អៀង, ឈ្មោះ [redacted] ធឿន, និងឈ្មោះ [redacted]រម្យ មេធាវីការពារ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លី។

សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៩២ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]អៀង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៨៣ (កប៥) ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ ឆ្លងតាមចម្លើយជនជាប់ចោទ និងតាមការសន្និដ្ឋានរបស់ថ្នាក់ក្រោម ឃើញថាគ្រប់គ្រាន់ សុំតម្កល់ការចោទប្រកាន់ដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨៨ "គ" ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted]អៀង ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ៨៣ "កប៥" ចុះថ្ងៃទី០៨ ខែកញ្ញា

ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៨៣ "កប៥" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី។

•សាលដីកានេះជំនុំជម្រះចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ ស[redacted]អៀង ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ បើកផ្លូវប្តឹងសាទុក្ខ ក្នុងរយៈពេលដែលច្បាប់កំណត់។

-បានឃើញបណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted]អៀង ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨៨ "គ" ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសារណាការពាររបស់ឈ្មោះ [redacted] មេធាវីការពារឲ្យឈ្មោះ [redacted]អៀង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted]អៀង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌ៨៨ (គ) ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted]អៀង នាពេលសវនាការថា: មុនថ្ងៃកើតហេតុ ខ្លួនទៅផឹកស៊ីនៅពោធិចិនតុងកន្លែងដើមត្នោត ដែលមានអ្នកលក់២នាក់ ហើយខ្លួនមានគ្នា៣នាក់ដែលខ្លួនជាអ្នកបើកម៉ូតូម៉ាកស្ទាស់ ជារបស់ខ្លួនបានទិញយូហើយ។ នៅយប់នោះមានម៉ូតូ២គ្រឿង ម៉ូតូខ្លួន១គ្រឿង និងឈ្មោះ [redacted] រម្យ និង[redacted] ធឿន ១គ្រឿង ម៉ាកសង់ពណ៌ខ្មៅ ជិះទន្ទឹមគ្នាដោយខ្លួនមិនដឹងថាឈ្មោះ [redacted] ធឿន ធ្វើអ្វីទេ ពេលជិះដល់ភ្លើងស្តុបក៏ត្រូវប៉ូលីសចាប់ខ្លួនតែម្តង។ ចំណែកឈ្មោះ [redacted] ធឿន មិនបាននិយាយអ្វីមុនពេលចាប់ខ្លួនទេ។

សំណូមពរ៖ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសអោយខ្លួនផង។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក [redacted] មេធាវីការពារអោយជនជាប់ចោទ នាពេលសវនាការថា៖ សុំឱ្យតុលាការពិចារណាលើចំលើយរបស់កូនក្តីខ្លួនដែលមានមុខរបររកស៊ីរត់



Scanned by CamScanner

67/2

ឡានឈ្នួលពីភ្នំពេញទៅកំពង់ចាម។ នៅពេលដែលកូនក្តីខ្លួន ទៅផឹកស៊ីជាមួយឈ្មោះ [redacted] ជឿន និង ឈ្មោះ [redacted] រម្យ ពេលធ្វើដំណើរឈ្មោះ [redacted] ជឿន បានបញ្ជាឱ្យកូនក្តីខ្លួនជិះម៉ូតូអែបស្តាំបន្តិចដោយ មិនដឹងពីគោលបំណងអ្វីទេ ពេលនោះកូនក្តីខ្លួនក៏បានអែប ប៉ុន្តែក្នុងពេលនោះការនឹកស្មានមិនដល់គឺ [redacted] ជឿន ធ្វើសកម្មភាពឆក់ខ្សែកជនរងគ្រោះតែម្តង។ យោងតាមអង្គហេតុនេះ កូនក្តីខ្លួនមិនមានការ បង្ហាញឆន្ទៈចូលរួមពីការធ្វើសកម្មភាពឆក់ខ្សែកនេះទេ តាមបញ្ញត្តិមាត្រា៤ នៃក្រមព្រហ្មទណ្ឌចែង ថាពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។

-សំណូមពរ សុំឱ្យតុលាការសម្រេចបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួន។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: គ្មាន យោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងមេធាវីការពារអោយជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**<u>តុលាការកំពូល</u>**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] អៀង ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

-យល់ឃើញថា ទោះបីជាជនជាប់ចោទឈ្មោះ [redacted] អៀង បានឆ្លើយនៅពេលសវនាការ ថា ខ្លួនបានឌុបឈ្មោះ [redacted] ជឿន នៅថ្ងៃកើតហេតុ។ តែខ្លួនមិនបានដឹងថាឈ្មោះ [redacted] ជឿន ធ្វើ សកម្មភាពអ្វីទេ។ ចំលើយនេះគ្រាន់តែជាការដោះសារតែប៉ុណ្ណោះ ពីព្រោះថាតាមចម្លើយរបស់ ឈ្មោះ [redacted] ជឿន បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលនៃកិច្ចស៊ើបសួររបស់សាលាដំបូងថា ខ្លួន និងឈ្មោះ [redacted] អៀង បានស្រុះស្រួលគ្នាជាមុនដើម្បីធ្វើសកម្មភាពប្លន់ខ្សែករបស់ជនរងគ្រោះ នៅពេលខ្លួនឃើញជនរងគ្រោះ ពាក់ខ្សែកជិះម៉ូតូតែម្នាក់ឯង ខ្លួនបានឱ្យឈ្មោះ [redacted] អៀង អែប ម៉ូតូក្បែរជនរងគ្រោះដើម្បីឆក់ខ្សែកពិតប្រាកដមែន ហើយឈ្មោះ [redacted] រម្យ ជាអ្នកជិះម៉ូតូបិទគូទពី ក្រោយ។

-យល់ឃើញថា តាមមាត្រា១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ហេតុរបស់មន្ត្រីនគរបាល យុត្តិធម៌ ត្រូវទុកជាបន្ទាល់ មានន័យថាត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។ ជនជាប់ចោទពុំមានភស្តុតាងផ្ទុយណាមកបញ្ជាក់ក្រៅតែពីចម្លើយរបស់ជនជាប់ចោទខ្លួនឯងដែលពុំ អាចឱ្យតុលាការជឿបានទេ។



Scanned by CamScanner

ឃើញថា ចម្លើយរបស់ជនជាប់ចោទទាំងបីនាក់ ចម្លើយរបស់ជនរងគ្រោះ និងសាក្សីព្រមទាំងវត្ថុតាងដែលរឹបអូសបាន មានលក្ខណៈស៊ីសង្វាក់ដែលបង្ហាញឱ្យឃើញពីគម្រោងការណ៍ក្នុងការធ្វើសកម្មភាពប្លន់ខ្សែកពីជនរងគ្រោះ។

-យល់ឃើញថា ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋនេះ ត្រូវបាននិរាករណ៍ដោយក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ហើយ។ ហេតុដូច្នេះ ជនជាប់ចោទឈ្មោះ [redacted]អៀង គប្បីទទួលបានអត្ថប្រយោជន៍នៃការអនុវត្តច្បាប់ថ្មី តាមស្មារតីមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៨ "គ" ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ដែលបាន សំរេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ លើកលែងតែការសម្រេចផ្តន្ទាទោសចំពោះអំពើប្រព្រឹត្តរបស់ជនជាប់ចោទ ឈ្មោះ [redacted]អៀង ដែលបានសម្រេចនៅក្នុងចំណុចទី១ ក នៃសាលក្រមព្រហ្មទណ្ឌលេខ៨៣ "កប៥" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវបដិសេធចោល។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលផ្នែកខ្លះនៃបណ្តឹងសារទុក្ខលេខ៨៨ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ ស៊ឹម លឹមអៀង។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៨ "គ" ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍លើកលែងតែចំណុចទី១ ក នៃសាលក្រមព្រហ្មទណ្ឌលេខ៨៣ "កប៥" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវបដិសេធចោល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៧៧ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីសម្រេចជាថ្មីឡើងវិញ តាមចំណុចទី២ នៃសាលដីកាតុលាការកំពូលនេះ។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ ថ្ងៃទី 31 ខែ 5 ឆ្នាំ២០១៣
ក្រឡាបញ្ជី
[redacted]

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី 31 ខែ 5 ឆ្នាំ២០១៣
ជ.ប្រធានតុលាការកំពូល
អនុប្រធាន
[redacted]



Scanned by CamScanner